# សេចក្តីជូនដំណឹង

## ស្តីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ទទួលជ្រាប ថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១** ធនាគារនឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញរបស់ធនាគារ តាមរយៈ **អ៊ីម៉ែល** ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១** នៅម៉ោង **១៤:០០ រសៀល** នូវរបៀបវារៈដូចខាងក្រោម៖

១) អនុម័តលើការតែងតាំង អ្នកស្រី Ratana Phurik ជាអភិបាលឯករាជ្យ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Ian S. Lydall;

២) អនុម័តលើការតែងតាំង លោក Kyosuke Hattori មកពី SMBC ជាអភិបាល អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Kenichiro Mori; និង

៣) អនុម័តលើការធ្វើវិសោធនកម្ម មាត្រា៧ មាត្រា៨ ឧបសម្ព័ន្ធទី១ ឧបសម្ព័ន្ធទី៣ និងការបន្ថែមឧបសម្ព័ន្ធទី៤ (ថ្មី) នៃលក្ខន្តិកៈធនាគារ អេស៊ីលីដា ភីអិលស៊ី។

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក**នៅកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** នឹងទទួលបាននូវលិខិតអញ្ជើញ ឯកសារគាំទ្រ ការណែនាំអំពីការបោះឆ្នោត លិខិតប្រគល់សិទ្ធិ និង QR Code សម្រាប់បោះឆ្នោត ដែលធនាគារនឹងផ្ញើជូនតាមរយៈអ៊ីម៉ែល។ ករណីដែលភាគហ៊ុនិកណាម្នាក់ពុំអាចចូលរួមការបោះឆ្នោតតាមកាលបរិច្ឆេទកំណត់បាន អាចផ្តល់សិទ្ធិប្រទានទៅឲ្យអ្នកតំណាងណាម្នាក់ ដើម្បីបោះឆ្នោតជំនួស ដោយគ្រាន់តែជូនដំណឹងមកធនាគារ ឬភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ យ៉ាងយូរត្រឹម**ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១** តាមរយៈមធ្យោបាយអេឡិចត្រូនិក។

ដំណើរការនៃការបោះឆ្នោតមានដូចខាងក្រោម៖

- ធនាគារនឹងផ្ញើ QR Code សម្រាប់បោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗ តាមរយៈអ៊ីម៉ែល ចាប់ពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ម៉ោង ១៤:០០ រសៀល (ម៉ោងនៅភ្នំពេញ)។
- ភាគហ៊ុនិកម្នាក់ៗ ត្រូវបោះឆ្នោតនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ក្នុងចន្លោះពេលណាមួយ ចាប់ពីម៉ោង **១៤:០០ ដល់ម៉ោង ១៦:០០ រសៀល** (ម៉ោងនៅភ្នំពេញ) ដោយបើកកាមេរ៉ាទូរស័ព្ទដៃ ឬ Tablet របស់លោក/អ្នក រួចស្កេន QR Code សម្រាប់បោះឆ្នោតដែលបានភ្ជាប់ជូនមកជាមួយនឹងអ៊ីម៉ែល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកិច្ចប្រជុំនេះតាមរយៈអ៊ីម៉ែលតាមកាលបរិច្ឆេទកំណត់ ដោយសេចក្តីអនុគ្រោះ។ ប្រសិនបើលោក/អ្នកមានតម្រូវការ ឬសំណួរផ្សេងៗ សូមទំនាក់ទំនងមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដូចខាងក្រោម៖

- **លោក លីម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ➢ ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
  - ➢ អ៊ីម៉ែល: lim.an@acledabank.com.kh

- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - ➢ ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - ➢ អ៊ីម៉ែល: huot.sophy@acledabank.com.kh

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - ➢ ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - ➢ អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃពុធ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**